## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៣ ខែ មិនា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៩០,៩០០ ដុល្លារអាមេរិក សម្រាប់បោះពុម្ពឯកសារពត៌មានស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០១២



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុននឹងផ្តល់ទឹកប្រាក់សរុបចំនួន ៩០,៩០០ ដុល្លាអាមេរិក ដល់គណៈកម្មាធិការតស៊ូមតិនៃសមាគមអង្គការមិនមែនរដ្ឋាភិបាល សម្រាប់គម្រោងបោះពុម្ពឯកសារពត៌មានស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១២ ។ កិច្ចសន្យាផ្តល់ជំនួយនេះត្រូវបានចុះហត្ថលេខាដោយលោក កាវ៉ាមូរ៉ា ហ៊ីរ៉ូស៊ី ឧបទូតស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកម៉ុក ម៉ែ ប្រធានគណៈកម្មាធិការតស៊ូមតិនៃសមាគម-អង្គការមិនមែនរដ្ឋាភិបាលនៅស្ថានទូតជប៉ុន។

ដើម្បីផ្តល់ពត៌មានស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១២ ដល់អ្នកបោះឆ្នោត គណៈកម្មាធិការតស៊ូមតិនៃសមាគម-អង្គការមិនមែនរដ្ឋាភិបាលនឹងបោះពុម្ពសេចក្តីណែនាំដល់អ្នកបោះឆ្នោតដែលមានបញ្ចូលពត៌មានចាំបាច់អំពីការបោះឆ្នោត។ ជាមួយសេចក្តីណែនាំនេះ អ្នកបោះឆ្នោតនឹងត្រូវបានផ្តល់ពត៌មានអំពីសិទ្ធិក្នុងការបោះឆ្នោត នីតិវិធី និងដំណើរការនៃការបោះឆ្នោត។ គម្រោងនេះនឹងធ្វើឲ្យអ្នកបោះឆ្នោតជាង៣លាននាក់នៅទូទាំងប្រទេសអាចទទួលបានពត៌មានស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅខែមិថុនា ឆ្នាំ២០១២នេះ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ ( *ជំនួយគូសាណូណិ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៤៧លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៤៦៨គម្រោងនៅទូទាំងប្រទេស។




ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០

អ៊ីមែល: eco.jpn@.pp.mofa.go.jp

គេហទំព័រ: http://www.kh.emb-japan.go.jp